# រឿង មហាចោរនៅទល់ដែន

## ភាគទី៧៣ (ជោគជ័យ)

ស្រីនៅស្ងៀមផ្អឹង ទន្ទេញតែក្នុងពោះថា:

គាត់ស្លាប់បាត់ទៅហើយ! អញប្រាកដជាគាត់ស្លាប់ រួចឥឡូវគាត់និយាយរកអញ! រួចគាត់មកនៅនឹងមុខអញទៀត!

ពេលនេះ មានន្ទបើកកន្សែងដែលដែលទទូរមុខឡើង។ ព្រះនាងខត្តិយាណីញ័ររន្ធត់សព្វសាច់។ វិញ្ញាណហិចហើរទៅណាអស់រលីង។ ចិត្តចង់សម្លាប់មានន្ទ សេចក្តីស្រែកឃ្លានចង់ស៊ីសាច់ សេចក្តីខ្លាច ស្លាប់នឹងដៃមានន្ទវិញ ក៏ហូរមកក្នុងចិត្តស្រីបន្តៗគ្នាឥតស្រាកស្រាន្ត។ ស្ទុះក្ដៅតយារកាំបិតហៀបចាក់ មានន្ទសើចផ្ចេចផ្ចែកនៅស្ងៀមផ្អឹង ហាក់ទទួចចង់កាំបិកនេះដោយរីករាយ។

ព្រះនាងដែលឆេះពេញខ្លួនមកចាញ់ៗ ទឹកមុខ ទឹកចិត្តដ៏ត្រជាក់នេះជាថ្មីម្តងទៀត។

កាំបិតធ្លាក់ពីដៃស្រីប្រូសទៅលើក្តារ។ មានន្ទទៅជិតព្រះនាង មុខស្ងួតពោលថា:

អូន! អនុញ្ញាតឲ្យបងប្រាប់អូនម្តងទៀតចុះថា: អូនមានរូបល្អអូននៅក្មេង! ត្រឡប់ទៅសុរិន្ទ្រវិញទៅ! ធ្វើជាស្រីធម្មតា ដូចស្រីឯទៀតប៉ុណ្ណោះបានហើយ! អូនមុខជាបានសុខមិនខាន...។ តោងអូនស្រលាញ់សេចក្តីស្នេហា។ សេចក្តីស្នេហា គឺជាចរិករបស់ស្ត្រីទាំងអស់ និងជាចរិករបស់បុរសទាំងអស់។ ទោះព្រះរាជក្តី គេតែងតែស្រលាញ់ជរាប។ ទៅ! អូន ទៅចុះ! រួចសុំទុកអោយពួកយើងទាមទារដណ្តើមយករស្មីជីវិត គឺឯករាជ្យជាតិ និងសេរីភាពប្រជារាស្ត្រដែលមនុស្សត្រូវតែបាន មិនថាសៀម ចិន ភូមា ឬខ្មែរទេ។ អូនចង់សម្លាប់បង! ប៉ុន្តែអូនយំ។ ហេតុនេះហើយបានជាបងសូមប្រាប់អូនដោយមេត្រីភាពដូចបានរៀបរាប់មកស្រាប់។

តែបើអូនមិនស្តាប់បងទេ...អូនបង្ខំអោយបងប្រព្រឹត្តឃាតកម្មឧក្រិដ្ឋមិនខាន។ បងមិនចង់សម្លាប់មនុស្សទេ តែបើមនុស្សនោះចេះតែចង់រស់ម្នាក់ឯងហួសហេតុពេក បងប្រែជាចង់សម្លាប់មនុស្សនោះបែបនេះណាស់ទៅវិញ។

ព្រះនាងខត្តិយាណីពេបមាត់បញ្ចេញអាការៈកាច។ នាងហាក់ដូចគ្មានព្រឺអ្វីនឹងសំដីចុងបំផុតរបស់មានន្ទឡើយ។ តើអ្នកណាអាចដឹងថា ជីតាមានគ្រោងការណ៍អ្វីទៀត។ ស្រីនិយាយតបថា:

យើងជាខ្មាំងនឹងគ្នាជាជរាប។

អត្ថបទដោយ៖ មាស សុភាព

មានន្ទចង់ចញ្ចើមមុខឡើងក្រហម ដូចគេពោលភ្លើង។

បើដូច្នោះ គ្មានអ្វីផ្សះផ្សាយើងបានទេ! មានតែអាវុធ។

មានន្ទហូតដាវផ្ទាប់គល់កព្រះនាងឥតបង្អង់ឡើយ។ ព្រះនាងពេបមាត់។ ស្រីលាតត្រដាងដៃស្ដាំទៅមាត់ទ្វារមួយជិតនោះ ដើម្បីអោយមានន្ទមើលតាម។

គាប់ជួនពេលនោះ ទ្វារបើកក្ញេតឡើង។

ទាហានចូលមក។ លុះឃើញមានន្ទដែលតម្រង់ចុងដាវគល់កព្រះនាង ទាហានដកដាវខ្លួនគិតស្ទុះចូលមក តែធីតាពាដៃ:

កុំ! កុំ មានការអី?

ព្រះបាទម្ចាស់មាសំបុត្រមួយមកពីព្រះចៅក្រុងអយុធ្យា។

អើ! យកមកមើល។

ទាហានចូលមកធ្វើគារវកិច្ច រួចហុចសំបុត្រ។ ព្រះនាងលាមើលរួចហុចសំបុត្រនេះទៅឲ្យមានន្ទមើលដូចតទៅ:

ពីព្រះចៅក្រុងអយុធ្យា ដល់ព្រះនាងខត្តិយាណីកែវមណី

ខ្ញុំព្រះចៅក្រុងអយុធ្យា បានទទួលលិខិតរាយការណ៍ អំពីមហាចោរមានន្ទហើយ និងអំពីកម្លាំងទ័ពយើង ដែលនៅស្ទួចស្ទើងនៅឡើយ។

ជាដំបូងខ្ញុំមានព្រះទ័យត្រេកអរនិងព្រះនាងណាស់ ដោយបានប្រឹងប្រែងពុះពារការលំបាកគ្រប់យ៉ាងដើម្បីទប់ទល់ការគ្រប់គ្រងរបស់ជាតិសៀមយើងក្នុងអាណាខេត្តសិរីសោភ័ណ។ សូមព្រះនាងបន្តការងាររយើងទៅទៀត។ ខ្ញុំបញ្ជូនមកជាមួយនេះនូវកងពលចំនួនប្រាំពាន់អ្នក ក្រោមការដឹកនាំរបស់សេរីវង្សម្តុជជាមួយនឹងមាសចំនួនកន្ទះហាប ដើម្បីបង្ក្រាបចលាចល សូមព្រះនាងប្រើប្រាស់តាមតម្រូវការ។

ខ្ញុំសូមអោយទេវតាជួយថែរក្សាព្រះនាង និងស្វេតច័ត្រឲ្យបានគង់វង្សយឺនយូររាប់លានឆ្នាំទៅមុខកុំខាន។

ព្រះចៅក្រុងអយុធ្យា

អត្ថបទដោយ៖ មាស សុភាព

ព្រះនាងញញឹម ងក់ក្បាលបញ្ជាឲ្យទាហាន:

ទៅចុះ! ឯចំណែកខាងបង សុំដាក់ដាវចុះ។

មានន្ទញីសំបុត្រទៅលើក្ដារ។ ព្រះនាងបន្តទៀតថា:

បងចង់សម្លាប់ប្អូន? ហ៊ឹះ! បងមិនយំ ដូចប្អូននឹងបងទេ! ទេ។ កុំសម្លាប់ពីព្រោះ...គ្រាន់តែថា ប៉ុណ្ណោះទ្វារមួយទៀតបើកឡើង។ ពេជ្ឈឃាតពីរនាក់មកចាប់ដៃ នាងទេវីម្នាក់ម្ខាង។ ផ្ដោតចុះកាំបិត នឹងកនាង។ មាត់នាងត្រូវគេចុកណែនរកស្រែកពុំរួច។

កាលបើឃើញមានន្ទ នាងកញ្ជ្រោលអស់ទំហឹងចង់ស្ទុះមករកមានន្ទ។

រីឯមានន្ទ កាលបើឃើញនាងទេវីដែលអ្នកស្មានថា ស្លាប់បាត់ទៅហើយនោះ បុរសហៀបស្ទុះទៅចាប់ តែសំលេងនាងមណីគំហកថា:

នៅស្ងៀម! បើបងកម្រើកតែបន្តិច ទេវីស្លាប់ហើយ!

មានន្ទមុខឡើងស្លាំង ញ័រដូចកូនសត្វ។ តើធ្វើយ៉ាងណា?

នាងមណីធ្វើព្រងើយ ផ្អែកខ្នងទៅនឹងសសរ និយាយថា:

ដាវបងនៅមួយចំអាមពីកខ្ញុំ។ ដាវខ្ញុំនៅជាប់នឹងកនាងទេវី។ បងឃើញទេ? ខ្ញុំដើរមុខបងជានិច្ច។ ឥឡូវសម្រេចយ៉ាងណាសម្រេចទៅ! ឬមួយលែងខ្ញុំអោយរស់ នាងទេវីក៏រស់ ឬមួយសម្លាប់ខ្ញុំ នាងទេវីក៏ស្លាប់។

មានន្ទប្រឹងនៅស្ងៀម។ ក្នុងវិនាទីនេះ ចិត្តពីរបញ្ច្រាស់គ្នាមកទង្គិចគ្នាយ៉ាងខ្លាំងក្នុងខ្លួនអ្នក។

ចិត្តទីមួយ អាណិតស្រណោះ ស្រលាញ់នាងទេវីបណ្ដូលចិត្តដោយព្រាត់យូរហើយ។ ដែលជាទីគោរពក្រៃពេក។ ស្រីស្រស់ល្អបរិសុទ្ធរកគ្មាន ថែមទាំងមានចិត្តស្នេហាអ្នកពិតៗពេញសុដនស្រី។ មើលចុះទឹកមុខនាងដែលពុំដែលបានសប្បាយ ចិញ្ចើមនាងដែលខ្មៅដូចគេគូរ ភ្នែកនាងដែលរលើបរលង់ទៅដោយទុក្ខ...

**(សូមរង់ចាំតាមដានភាគទី៧៤ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព